# ឯកឧត្តមទេសរដ្ឋមន្ត្រី **ចម ប្រសិទ្ធ** ស្នើឲ្យអង្គការ JICA ពិនិត្យលទ្ធភាពបង្កើតរោងចក្រផលិតទឹកស្អាតនៅខេត្តស្វាយរៀង



ក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងារជាមួយលោក ADACHI Itsu ប្រធានតំណាងអង្គការ JICA ប្រចាំកម្ពុជា ដែលបានបញ្ចប់អណត្តិនៅកម្ពុជារយៈពេល២ ឆ្នាំ និងលោក SUGANO Yuichi ប្រធានតំណាងថ្មីប្រចាំកម្ពុជា ព្រមទាំងសហការី នៅទីស្តីការក្រសួង នារសៀលថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០១៧ ឯកឧត្តមទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានវាយតម្លៃខ្ពស់ចំពោះលោកប្រធានចាស់ ក្នុងកិច្ចសហការដ៏ល្អជាមួយក្រសួង ក្នុងការអនុវត្តគម្រោងនានា ជាពិសេសលើវិស័យទឹកស្អាត គឺប្រទេសជប៉ុនតាមរយៈអង្គការ JICA បានជាប់ឈ្មោះដ៏ល្អនៅកម្ពុជា ។

ជាក់ស្តែងរដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានទទួលពានរង្វាន់លើគុណភាពទឹកស្អាតជាបន្តបន្ទាប់ពីស្ថាប័នវាយតម្លៃអន្តរជាតិនានា ។

ឯកឧត្តមទេសរដ្ឋមន្ត្រីបានបន្តថាវិស័យទឹកស្អាត ក្រោមគម្រោងរបស់អង្គការ JICA គឺមានវិសាលភាពគ្របដណ្តប់តាមទីប្រជុំជន និងបណ្តាខេត្តសំខាន់ៗមួចំនួន ដូចជា បាត់ដំបង កំពង់ចាម សៀមរាប កំពង់ធំ កំពត និងមណ្ឌលគីរី ជាដើម ។ បញ្ហានេះ ឯកឧត្តមទេសរដ្ឋមន្ត្រីស្នើឲ្យអង្គការ JICA ពិនិត្យលទ្ធភាព ការបង្កើតរោចក្រផលិតទឹកស្អាត នៅខេត្តស្វាយរៀងផងដែរ ។

ជាមួយនិងការស្វាគមន៍ចំពោះប្រធានតំណាងអង្គការ JICA ថ្មី នៅកម្ពុជា ឯកឧត្តមទេសរដ្ឋមន្ត្រី សង្ឃឹមថាលោកប្រធានថ្មី នឹងសហការល្អបន្តទៀតជាមួយក្រសួង ដែលក្រៅពីវិស័យទឹកស្អាត លោកបានស្នើសហការគាំទ្រការលើកកំពស់វិស័យ សហគ្រាសធុនតូច និងមធ្យម ការបណ្តុះបណ្តាលធនធានមនុស្ស និងពង្រឹងសមត្ថភាពស្ថាប័ន ។

លោក SUGANO Yuichi ប្រធានតំណាងថ្មីប្រចាំកម្ពុជា នៃអង្គការ JICA បានបង្ហាញនូវជំហរសហការគាំទ្រ និងផ្តល់សារៈសំខាន់ចំពោះមតិ និងសំណើររបស់ ឯកឧត្តមទេសរដ្ឋមន្ត្រី ខាងលើ។





